**MEDIA STATEMENT**

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# ជនរងគ្រោះដោយអំពើទារុណកម្ម មិនត្រូវប្រឈមមុខនឹងការសងសឹក ដោយសារតែស្វែងរកការដោះស្រាយតាមរយៈអង្គការសហប្រជាជាតិឡើយ

*សេចក្តីថ្លែងការណ៍រួម* កត់សំគាល់ទិវាអន្តរជាតិអង្គការសហប្រជាជាតិ ក្នុងការគាំទ្រដល់ជនរងគ្រោះដោយអំពើទារុណកម្ម ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២*

**ទីក្រុងហ្សឺណែវ** (ថ្ងៃ២៦ មិថុនា ២០១២) បុរសម្នាក់ដែលត្រូវគេឃុំខ្លួនតាមទំនើងចិត្ត បានមកជួបស្ថាប័នសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដើម្បីស្វែងរកយុត្តិធម៌។ ខណៈពេលដែលស្ថាប័នអង្គការសហប្រជាជាតិសំរេចគាំទ្រគាត់ បុរសនោះប្រឈមនឹងការសងសឹកយ៉ាងធ្ងន់ធ្ងរ ដោយសារតែការដែលគាត់និយាយអះអាងការពារសិទ្ធិរបស់ខ្លួនគាត់។ គាត់ត្រូវបានគេបដិសេធការពិនិត្យព្យាបាលផ្នែកវេជ្ជសាស្រ្ត ត្រូវបានគេដាក់បង្ខាំងឲ្យនៅតែម្នាក់ឯងដាច់ពីគេ និងបានអះអាងថា ត្រូវបានអាជ្ញាធរពន្ធនាគារការវាយដំ។

ថ្ងៃនេះ នៅក្នុងទិវាអន្តរជាតិគាំទ្រជនរងគ្រោះដោយអំពើទារុណកម្ម យើងទាំងអស់គ្នា សូមដាស់តឿនដល់រដ្ឋទាំងអស់ថា រដ្ឋមានកាតព្វកិច្ចការពារបុគ្គលដូចនេះ និងត្រូវធានាថា ពួកគាត់មិនត្រូវប្រឈមមុខនឹងការសងសឹក ការបំភិតបំភ័យ ដោយសារតែពួកគាត់សហការជាមួយស្ថាប័នអង្គការសហប្រជាជាតិឡើយ។

រៀងរាល់ឆ្នាំ គណៈកម្មាធិការប្រឆាំងទារុណកម្ម និងអ្នកជំនាញការឯករាជ្យទាំងឡាយ ដែលបានតែងតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ទទួលលិខិតជាឯកត្តបុគ្គលពីជនរងគ្រោះដោយអំពើទារុណកម្ម និងព័ត៌មានអះអាងពីការរំលោភបំពានផ្សេងៗ បានមកពីអ្នកការពារសិទ្ធិមនុស្ស និងតួអង្គសង្គមស៊ីវិលពីគ្រប់តំបន់ជុំវិញពិភពលោក ដើម្បីពិនិត្យពិចារណាក្នុងរបាយការណ៍របស់ខ្លួន។ ជនជាប់ឃុំជាច្រើន ដែលហានិភ័យផ្ទាល់ខ្លួនមានកំរិតខ្ពស់ មានសេចក្តីក្លាហានក្នុងការចែករំលែកបទពិសោធន៍ជូរចត់របស់ខ្លួនអំពីទារុណកម្ម និងការធ្វើបាប ប្រាប់អនុគណៈកម្មាធិការបង្ការទារុណកម្ម និង អ្នករាយការណ៍ពិសេសស្តីពីទារុណកម្ម និងនៅក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចរបស់ពួកគាត់ទៅកាន់មជ្ឈមណ្ឌលឃុំឃាំងនានា។

រៀងរាល់ឆ្នាំ មជ្ឈមណ្ឌលស្តារនីតិសម្បទាតូចធំរាប់រយកន្លែង ដែលបានគាំទ្រពីមូល នីធិស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិសំរាប់ជនរងគ្រោះដោយអំពើទារុណកម្ម ផ្តល់ការជួយឧបត្ថម្ភចាំបាច់

ផ្នែកច្បាប់ វេជ្ជសាស្ត្រ និងមនុស្សធម៌ ដល់ជនរងគ្រោះរាប់ពាន់នាក់ និងសមាជិកគ្រួសាររបស់ពួកគាត់។

ភាគច្រើននៃជនរងគ្រោះ និងតួអង្គទាំងឡាយ ដែលអាចឲ្យយើងធ្វើការបាន តាមរយៈការផ្តល់ជំនាញដ៏សំខាន់ និងការចែករំលែកបទពិសោធន៍នៃការឈឺចាប់ ការបំភិតបំភ័យ និងការសងសឹក។

ការសងសឹកចំពោះបុគ្គលទាំងឡាយ ដែលសហការជាមួយយន្តការអង្គការសហប្រជាជាតិក្នុងការការពារ និងលើកស្ទួយសិទ្ធិមនុស្សគឺជាការដែលមិនអាចទទួលយកបានជាដាច់ខាត ហើយវាជាការរំលោភលើច្បាប់អន្តរជាតិ និងកាតព្វកិច្ចច្បាប់របស់រដ្ឋ។ ត្រូវតែមានមធ្យោបាយមួយមានប្រសិទ្ធិភាព ដើម្បីធានាថា ការសងសឹកមិនអាចកើតមានឡើយ ហើយប្រសិនជាកើតមាន បុគ្គលទាំងឡាយដែលពាក់ព័ន្ធ និងរដ្ឋ ត្រូវតែទទួលខុសត្រូវ។

ក្រោមអនុសញ្ញាប្រឆាំងទារុណកម្ម រដ្ឋទាំងឡាយមានកាតព្វកិច្ចចាត់វិធានការ ដើម្បីធានាថា បណ្តឹង និងសាក្សី ឬបុគ្គលណាមួយ ឬអង្គការដទៃទៀត ដែលសហការជាមួយគណៈកម្មាធិការ ត្រូវទទួលការពារប្រឆាំងនឹងការធ្វើបាប ការបំភិតបំភ័យ ឬការសងសឹក។ ស្រដៀងគ្នានេះដែរ អនុគណៈកម្មាធិការបង្ការទារុណកម្ម អំពាវនាវដល់រដ្ឋភាគីនានា ឲ្យគោរពទាំងស្រុងនូវកាតព្វកិច្ចរបស់ខ្លួន ក្រោមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម ដើម្បីធានាថា បុគ្គលទាំងឡាយដែលអនុគណៈកម្មាធិការនេះ ជួបនៅក្នុងអំឡុងពេលបំពេញទស្សនកិច្ចរបស់ខ្លួន មិនត្រូវបានដាក់ទណ្ឌកម្មដោយសារតែការសហការរបស់ពួកគាត់ឡើយ។

ក្នុងការជំរុញឲ្យរដ្ឋនានា បង្កើត និងគាំទ្រមជ្ឈមណ្ឌល ឬសេវាស្តារនីតិសម្បទា ជាកន្លែងដែលជនរងគ្រោះអាចទទួលការពិនិត្យព្យាបាល មហាសន្និបាតបានចែងនាពេលថ្មីៗនេះថា រដ្ឋទាំងឡាយគួរតែធានាផងដែរ នូវសុវត្ថិភាពរបស់អ្នកជម្ងឺ និងបុគ្គលិករបស់ខ្លួន។

នៅថ្ងៃនេះ យើងទាំងអស់គ្នារួមសាមគ្គីគ្នាជាមួយបុគ្គលទាំងឡាយដែល (បន្ទាប់ពីបានទទួលរងការឈឺចាប់ដោយទម្រង់អាក្រក់បំផុតនៃអំពើទារុណកម្ម និងការធ្វើបាប) ដាក់ការជឿទុកចិត្តរបស់ខ្លួនលើយន្តការអង្គការសហប្រជាជាតិ ទោះជាប្រឈមមុខនឹងហានិភ័យនៃការសងសឹកក្តី។ វាជាការចាំបាច់ណាស់ដែលថា រដ្ឋទាំងឡាយត្រូវតែប្រែក្លាយការសន្យារបស់ខ្លួន ឲ្យទៅជាការប្រយុទ្ធប្រឆាំងនឹងអំពើទារុណកម្ម ដោយការចាត់វិធានការផ្សេងៗដើម្បីធានាថាជនរងគ្រោះ និងសកម្មជនសិទ្ធិមនុស្សដែលសហការជាមួយយន្តការអង្គការសហប្រជាជាតិប្រឆាំងទារុណកម្ម មិនត្រូវស្ថិតក្រោមការសងសឹក និងការក្លាយជាជនរងគ្រោះសារជាថ្មីឡើយ។

(*) សេចក្តីថ្លែងការណ៍រួមនេះ ត្រូវបានចេញដោយគណៈកម្មាធិការអង្គការសហប្រជាជាតិប្រឆាំងទារុណកម្ម អនុគណៈកម្មាធិការបង្ការទារុណកម្ម អ្នករាយការណ៍ពិសេសប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប និងក្រុមប្រឹក្សាភិបាលនៃមូលនិធិស្ម័គ្រចិត្តអង្គការសហប្រជាជាតិសំរាប់ជនរងគ្រោះនៃអំពើទារុណកម្ម។

**ចប់**

*សំរាប់ព័ត៌មានបន្ថែម និង ការសាកសួរព័ត៌មានផ្សេងៗ សូមមេត្តាទាក់ទងជាមួយអ្នកនាំពាក្យ ឈ្មោះ រ៉ាប់ភឺត ខូលវីល (+41 22 917 9767 / rcolville@ohchr.org) ឬមន្ត្រីសារព័ត៌មាន ឈ្មោះ រ៉ាវីណា សេមដាសានី (+ 41 22 917 9310 / rshamdasani@ohchr.org)*

*គណៈកម្មាធិការប្រឆាំងទារុណកម្ម ៖ http://www2.ohchr.org/english/bodies/cat/*

*អ្នករាយការណ៍ពិសេសប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ៖*
*http://www.ohchr.org/EN/Issues/Torture/SRTorture/Pages/SRTortureIndex.aspx*

*អនុគណៈកម្មាធិការបង្ការទារុណកម្ម៖*
*http://www2.ohchr.org/english/bodies/cat/opcat/index.htm*

*មូលនិធិស្ម័គ្រចិត្តអង្គការសហប្រជាជាតិសំរាប់ជនរងគ្រោះនៃអំពើទារុណកម្ម ៖*
*http://www.ohchr.org/EN/Issues/Pages/TortureFundMain.aspx*

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងតាមរយៈព័ត៌មានសង្គម ៖**
**ហ្វេសប៊ុក ៖** https://www.facebook.com/unitednationshumanrights
**ទ្វីតធឺ ៖** http://twitter.com/UNrightswire
ហ្គោហ្គ៏ល៖ Google+ gplus.to/unitednationshumanrights
**យូធូប ៖** http://www.youtube.com/UNOHCHR

ចូលរួមជាមួយយើងនិយាយខ្លាំងៗអំពីសិទ្ធិមនុស្សនៅក្នុងកិច្ចប្រជុំ Rio+20 ប្រើ**#RightsRio**